អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងវដ្តនៃទឹកភ្លៀង**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំងថ្ងៃ (ការស្វែងយល់ដោយសង្កេត)

បំណិនពិចារណា (ការយល់ដឹងអំពីហេតុ និងផល)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។
បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីរបៀបនៃការពិសោធន៍។
លក្ខណៈរបស់អាកាសធាតុ ស្ថានភាពវត្ថុអ្វីមួយ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើនរណាជាអ្នកលាបពណ៌មេឃ?”

**រយៈពេល** ៖ ៣០ នាទី

**រយៈពេល** ៖៣០នាទី

**ឧបករណ៍** ៖ សន្លឹកសិច្ចការ (B3-PW-4_ល្បែងគូសតាមស្នាមចុចទឹកភ្លៀង) និងខ្មៅដៃពណ៌

**ការរៀបចំ** ៖ បោះពុម្ព ឬព្រីនសន្លឹកកិច្ចការ ។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងវដ្តនៃទឹកភ្លៀង**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗ៖ តើកូនៗស្គាល់ទឹកភ្លៀងដែរឬទេ? បាទ/ចាស ស្គាល់។
   តើភ្លៀងចាប់ផ្តើមនៅរដូវណា? រដូវវស្សា។
3. ប្រាប់ក្មេងៗ៖ អ្នកគ្រូនឹងត្រូវសម្តែងធ្វើជាវដ្តនៃទឹកភ្លៀង ចំណែកកូនៗនឹងត្រូវសម្តែងធ្វើជាទឹក។

4. ចែកក្មេងៗទៅជាក្រុមតូចៗ និងឱ្យពួកគេឈរជាក្រុមៗនៅតាមកន្លែងផ្សេងៗពីគ្នានៅក្នុងថ្នាក់។
5. ហើយមានគម្លៀតពីគ្នាសមល្មមដើម្បីងាយស្រួលធ្វើកាយវិការ ។
6. ឱ្យក្មេងៗទាំងអស់ក្រាបចុះ។
7. និយាយពាក្យថា "រំហួត ការបង្រួម និងដំណក់ទឹក" នៅពេលដែលអ្នកនិយាយពាក្យទាំងនេះគឺត្រូវធ្វើកាយវិការផង។
    - រំហួត ៖ លើកដៃឡើងលើយឺតៗ រហូតដល់កំពូល។
    - ការបង្រួម ៖ផ្លាស់ប្តូរទីទៅជិតៗអ្នកផ្សេងៗទៀតធ្វើដូចជាពពករសាត់ចូលគ្នា។
    - ដំណក់ទឹក ៖ ក្រាបចុះ (ធ្វើដូចជាទឹកភ្លៀងធ្លាក់ចុះក្រោម)។
8. និយាយពាក្យហ្នឹងម្តងទៀត និងឱ្យក្មេងៗទាំងអស់និយាយតាមអ្នក និងធ្វើកាយវិការដែរ។
9. នៅពេលដែលពួកគេនិយាយការបង្រួម ពួកគេគួរតែផ្លាសប្តូរទីកន្លែងទៅជិតក្មេងផ្សេងៗទៀតនៅក្នុងក្រុមរបស់ខ្លួន។
10. នៅពេលដែលពួកគេនិយាយរួចរាល់ជាមួយពាក្យដំណក់ទឹកនោះ ពួកគេគួរតែកន្ទេកជើងម្តងទៀតនៅក្នុងក្រុមរបស់ពួកគេ។
11. ឱ្យក្មេងៗធ្វើដោយខ្លួនឯងផ្ទាល់ដោយគ្មានការនិយាយអ្វីពីអ្នកផ្សេងឡើយ។
12. ចូរឱ្យក្មេងៗទាំងអស់អង្គុយចុះ។
13. ចូរចែកសន្លឹកកិច្ចការ និងខ្មៅដៃពណ៌។
14. ចូរឱ្យក្មេងៗទាំងអស់ផាត់ពណ៌លើសន្លឹកកិច្ចការរបស់ពួកគេ។